វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

អនុក្រឹត្យ/៩៣ អនក្រ.បក/២៧ មិថុនា ១៩៩៥/

ស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០-៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

សំរេច

មាត្រា១:

យោងតាមស្មារតី មាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា កោះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

មាត្រា២:

ក្នុងន័យនេះ ដីដែលដុះចាស់ ឬថ្មីជាកោះនៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួរ ទូទាំងព្រះរាជាណាក្រកម្ពុជា ត្រូវប្រកាសជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតអោយឯកជន ឬសមូហភាពណា ប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ។

មាត្រា៣:

សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអោយសំរេច តាមអនុក្រឹត្យនេះរៀងៗខ្លួន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះ ហត្ថលេខាតទៅ ។